# ការប្រតិព័ទ្ធភេទដូចគ្នា

ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

---

*ដកស្រង់ចេញមកពីប្រធានបទដំណឹងល្អនៅគេហទំព័រ topics.lds.org៖*

ការប្រតិព័ទ្ធភេទដូចគ្នាសំដៅទៅលើការប្រតិព័ទ្ធទៅលើមនុស្សម្នាក់ដែលមានភេទដូចគ្នាខាងសតិអារម្មណ៍ ខាងរូបកាយ ឬខាងផ្លូវភេទ ។ ការជាប់ទាក់ទងនឹងការប្រតិព័ទ្ធភេទដូចគ្នា គឺពុំដូចគ្នាទេចំពោះមនុស្សគ្រប់រូប ។ មនុស្សខ្លះអាចនឹងមានអារម្មណ៍ប្រតិព័ទ្ធយ៉ាងខ្លាំងទៅមនុស្សដែលមានភេទដូចគ្នា ខណៈដែលមនុស្សខ្លះទៀតអាចនឹងមានអារម្មណ៍ប្រតិព័ទ្ធទៅលើមនុស្សទាំងពីរភេទ ។

សាសនាចក្របង្ហាញពីលក្ខណៈខុសគ្នារវាងការប្រតិព័ទ្ធភេទដូចគ្នា និងឥរិយាបទនៃការរួមភេទដូចគ្នា ។ មនុស្សដែលមានការប្រតិព័ទ្ធភេទដូចគ្នា ឬត្រូវបានស្គាល់ថាជាមនុស្សខ្ទើយប្រុស មនុស្សខ្ទើយស្រី ឬមនុស្សខ្ទើយ អាចចុះ និងរក្សាសេចក្ដីសញ្ញាជាមួយព្រះ ហើយចូលរួមក្នុងសាសនាចក្រដោយពេញលេញ និងដោយសក្ដិសម ។ ការស្គាល់ថាជាមនុស្សខ្ទើយប្រុស មនុស្សខ្ទើយស្រី ឬមនុស្សខ្ទើយ ឬ មានការប្រតិព័ទ្ធភេទដូចគ្នា គឺពុំមែនជាអំពើបាបនោះទេ ហើយក៏មិនបានហាមប្រាមមិនឲ្យចូលរួមក្នុងសាសនាចក្រ មានការហៅបម្រើ ឬចូលរួមក្នុងព្រះវិហារបរិសុទ្ធនោះដែរ ។

ភាពបរិសុទ្ធខាងផ្លូវភេទ គឺជាផ្នែកដ៏សំខាន់មួយនៃផែនការរបស់ព្រះសម្រាប់សុភមង្គលរបស់យើង ។ ទំនាក់ទំនងខាងផ្លូវភេទ ត្រូវបានរក្សាសម្រាប់បុរសម្នាក់ និងស្ត្រីម្នាក់ដែលបានរៀបការ និងបានសន្យាថាមានភក្ដីភាពចំពោះគ្នាទៅវិញទៅមកទាំងស្រុង ។ ទំនាក់ទំនងខាងផ្លូវភេទរវាងបុរសម្នាក់ និងស្ត្រីម្នាក់ដែលពុំបានរៀបការ ឬរវាងមនុស្សដែលមានភេទដូចគ្នា គឺល្មើសនឹងក្រឹត្យវិន័យដ៏សំខាន់បំផុតមួយរបស់ព្រះវរបិតាដែលគង់នៅស្ថានសួគ៌របស់យើង ហើយវារាំងស្ទះដល់ការរីកចម្រើនដ៏អស់កល្បជានិច្ចរបស់យើង ។ មនុស្សដែលមានចេតនាខាងផ្លូវភេទណាមួយដែលល្មើសនឹងក្រឹត្យវិន័យនៃព្រហ្មចារីភាព អាចត្រូវបានផ្សះផ្សាជាមួយនឹងព្រះតាមរយៈការកែប្រែចិត្ត ។ ក្នុងនាមជាអ្នកដើរតាមព្រះគ្រីស្ទ យើងជំទាស់នឹងឥរិយាបទអសីលធម៌ ហើយព្យាយាមដើម្បីប្រែក្លាយដូចជាទ្រង់ ។ យើងស្វែងរកការណែនាំមកពីព្រះវិញ្ញាណបរិសុទ្ធ និងជំនួយមកពីព្រះអង្គសង្គ្រោះ ដែលស្គាល់របៀបជួយដល់យើង នៅពេលយើងត្រូវបានល្បួង ( សូមមើលគោលលទ្ធិ និងសេចក្ដីសញ្ញា ១០:១៣,គ និង ស ៦២:១) ។ ប្រសិនបើយើងចុះចាញ់តាមការល្បួងខាងផ្លូវភេទ ហើយល្មើសនឹងច្បាប់ព្រហ្មចារីភាព នោះយើងអាចប្រែចិត្ត អាចត្រូវបានអភ័យទោស ហើយចូលរួមនៅក្នុងការរាប់អានពេញលេញក្នុងសាសនាចក្រ ។

យើងអាចនឹងមិនដឹងជាក់លាក់ថាហេតុអ្វីមនុស្សខ្លះមានអារម្មណ៍ប្រតិព័ទ្ធអ្នកដទៃដែលមានភេទដូចគ្នានោះទេ ប៉ុន្តែចំពោះមនុស្សខ្លះវាគឺជាភាពពិតដ៏ស្មុគស្មាញមួយ ហើយវាជាចំណែកនៃបទពិសោធន៍មនុស្សលោក ។ ព្រះអង្គសង្គ្រោះ ព្រះយេស៊ូវគ្រីស្ទ ទ្រង់ញាណដឹងដ៏ឥតខ្ចោះអំពីឧបសគ្គទាំងអស់ដែលយើងជួបនៅលើផែនដីនេះ ហើយយើងអាចត្រឡប់ទៅរកទ្រង់សូមការលួងលោមចិត្ត អំណរ ក្ដីសង្ឃឹម និងការដឹកនាំ ( សូមមើលអាលម៉ា ៧:១១-១២) ។ មិនថាយើងជួបនឹងឧបសគ្គអ្វីខ្លះក្នុងជីវិតនេះទេ យើងទាំងអស់គ្នាគឺជាកូនចៅរបស់ព្រះ ដែលសមនឹងទទួលយកនូវសន្ដានចិត្តល្អ និងក្ដីមេត្តាករុណាពីគ្នាទៅវិញទៅមក (រ៉ូម ៨:១៦-១៧) ។ នៅពេលយើងបង្កើតបរិយាកាសគាំទ្រគ្នា នោះយើងស្ថាបនាសេចក្ដីសប្បុរស និងសេចក្ដីអាណិតអាសូរដល់គ្នាទៅវិញទៅមក ហើយទទួលបានផលប្រយោជន៍មកពីទស្សនវិស័យ និងជំនឿមេត្តារបស់យើង ។